ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមសីលធម៌វិជ្ជាជីវៈ

## ក្រុមហ៊ុនតេឆីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក

## បុព្វកថា

I. ការអភិវឌ្ឍសេដ្ឋកិច្ចតម្រូវឱ្យមានការបែងចែកមូលធនឱ្យបានសមស្របតាមរយៈទីផ្សារហិរញ្ញវត្ថុដែលមានលក្ខណៈស៊ីជម្រៅ និងដំណើរការល្អ។ មូលបត្រដែលមានប្រភេទ និងឥណប្រតិទានផ្សេងៗគ្នា អនុញ្ញាតឱ្យវិនិយោគិនសម្រេចបាននូវគោលដៅចំណូលស្របទៅតាមកម្រិតទទួលយក ហានិភ័យរបស់ខ្លួន។ បំណុលគឺជាសមាសធាតុសំខាន់នៃទីផ្សារហិរញ្ញវត្ថុ ទាំងតាមរយៈប្រព័ន្ធធនាគារ ឬការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងជួញដូរដោយផ្ទាល់នៅលើទីផ្សារមូលបត្រ។ ដើម្បីឱ្យទីផ្សារឧបករណ៍បំណុលដំណើរការប្រកបដោយភាពត្រឹមត្រូវ និងប្រសិទ្ធភាព វិនិយោគិនត្រូវទទួលបាននូវព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយ។

II. ភ្នាក់ងារវាយតម្លៃលទ្ធភាពសង (RACs) ដើរតួនាទីយ៉ាងសំខាន់ក្នុងការវាយតម្លៃទៅលើគុណភាពរបស់ក្រុមហ៊ុនបោះផ្សាយនិងឧបករណ៍បំណុលផ្សេងៗ, លក្ខណៈហានិភ័យ និងលទ្ធភាពនៃការមិនសងត្រឡប់ដែលមានបង្ហាញក្នុងការវាយតម្លៃលទ្ធភាពសង។ ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងគឺជាការបញ្ចេញទស្សនៈមួយ។ ការវាយតម្លៃនេះមិនមែនជាសេចក្ដីថ្លែងនូវការពិតណាមួយឡើយ។ ដូចនេះ ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងត្រូវធ្វើឡើងក្នុងដំណើរការមួយដែលផ្អែកទៅលើគោលការណ៍ទំនុកចិត្ត តម្លាភាព និងឯករាជ្យភាព។

III. **រេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក** ហៅកាត់ថា″ RAC″) ត្រូវបានបង្កើតឡើងដើម្បីផ្ដល់សេវាវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្រោមគោលការណ៍បីចំណុចខាងលើនេះ។ ការវាយតម្លៃនេះនឹងអនុវត្តវិធីសាស្ត្រនៃការវិភាគលទ្ធភាពសងដែលមានលក្ខណៈវិជ្ជាជីវៈ ច្បាស់លាស់ និងលម្អិត។ ការវាយតម្លៃនេះនឹងធ្វើឡើងប្រកបដោយតម្លាភាព ដើម្បីឱ្យវិនិយោគិន និយ័តករ និងអ្នកប្រើប្រាស់ទាំងអស់អាចធ្វើការវាយតម្លៃទៅលើលទ្ធផលនៃការវិភាគ។ ការវាយតម្លៃត្រូវធ្វើឡើងដោយមិនទទួលរងឥទ្ធិពល ការអន្តរាគមន៍ ឬទំនាស់ផលប្រយោជន៍ណាមួយឡើយ។

IV. ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ RAC នឹងប្រតិបត្តិដោយម៉ត់ចត់នូវ "ក្រមសីលធម៌វិជ្ជាជីវៈ″ ដែលដកស្រង់ចេញពីក្រមសីលធម៌វិជ្ជាជីវៈដែលចេញដោយអង្គការគណៈកម្មការមូលបត្រអន្តរជាតិ (International Organization of Securities Commissions –IOSCO)[១] សមាគមន៍ភ្នាក់ងារវាយតម្លៃលទ្ធភាពសងក្នុងតំបន់អាស៊ី (ACRAA), មូលដ្ឋានគ្រឹះនៃក្រមសីលធម៌វិជ្ជាជីវៈសម្រាប់ភ្នាក់ងារវាយតម្លៃលទ្ធភាពសងក្នុងស្រុក[២] និងសៀវភៅស្ដីពីឧត្តមានុវត្តអន្តរជាតិក្នុងការវាយតម្លៃលទ្ធភាពសងរបស់ធនាគារអភិវឌ្ឍអាស៊ី ADB។ ការណ៍នេះនឹងធានាថា RAC នឹងអនុវត្តបានតាមឧត្តមានុវត្តអន្តរជាតិ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

## ១-គុណភាព និងសុចរិតភាពនៃដំណើរការវាយតម្លៃលទ្ធភាពសង

## ក-គុណភាពនៃដំណើរការវាយតម្លៃលទ្ធភាពសង

១.១ RAC ត្រូវបង្កើត រក្សា ចងក្រងទុកជាឯកសារ និងអនុវត្តនូវវិធីសាស្ត្រនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងសម្រាប់ប្រភេទនីតិបុគ្គលនីមួយៗ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់វាយតម្លៃលទ្ធភាពសងពី RAC។ វិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនីមួយៗត្រូវមានភាពច្បាស់លាស់ និងអាចអនុវត្តបានប្រកបដោយសង្គតិភាព ហើយលទ្ធផលនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងគឺអាចអនុវត្តបានតាមទម្រង់នៃការត្រួតពិនិត្យដែលមានលក្ខណៈច្បាស់លាស់ដោយផ្អែកលើបទពិសោធន៍ពីមុន ប្រសិនមាន។[១]

១.២ ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងត្រូវឆ្លុះបញ្ចាំងនូវព័ត៌មានទាំងអស់ដែលពាក់ព័ន្ធទៅនឹង RAC ស្របតាមវិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលអាចអនុវត្តបានដែលមានសុពលភាព។ ដូចនេះ RAC ត្រូវបង្កើត រក្សា ចងក្រងទុកឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យ ដើម្បីធានាថាការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង និងរបាយការណ៍ពាក់ព័ន្ធដែលធ្វើការផ្សព្វផ្សាយគឺផ្អែកលើការវិភាគយ៉ាងម៉ត់ចត់ទៅលើព័ត៌មានទាំងអស់នោះ។

១.៣ RAC ត្រូវអនុម័តនូវវិធានការសមស្របដើម្បីធានាថាខ្លួនមានចំណេះដឹង និងជំនាញសមស្រប ហើយព័ត៌មានដែលត្រូវបានប្រើប្រាស់ក្នុងការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងត្រូវមានគ្រប់គ្រាន់ និងជាប្រភេទព័ត៌មានដែលទទួលបានពីប្រភពដែលអាចទុកចិត្តបាន ដើម្បីគាំទ្រដល់ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលមានគុណភាពខ្ពស់។

១.៤ RAC ត្រូវចៀសវាងនូវការចេញចំណាត់ថ្នាក់លទ្ធភាពសងចំពោះអង្គភាព ឬឧបករណ៍បំណុលក្នុងករណីដែលមិនមានព័ត៌មានច្បាស់លាស់ ចំណេះដឹង និងជំនាញសមស្រប។ ឧទាហរណ៍៖ ករណីមូលបត្រ ឬប្រភេទនៃមូលបត្រដែលមានភាពស្មុគស្មាញ ឬកង្វះទិន្នន័យជាក់លាក់អំពីទ្រព្យសកម្មដើមនៃប្រភេទមូលបត្រទាំងនោះ ដែលនាំឱ្យមាននូវសំណួរផ្សេងៗទៅលើប្រភេទមូលបត្រទាំងនោះ RAC ត្រូវធ្វើការបដិសេធក្នុងការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងទៅលើប្រភេទមូលបត្រទាំងនោះ។

១.៥ ក្នុងដំណើរការនៃការវាយតម្លៃទៅលើលទ្ធភាពសង អ្នកវិភាគដែលពាក់ព័ន្ធនឹងសកម្មភាពវាយតម្លៃនេះ ត្រូវប្រើប្រាស់វិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលបង្កើតឡើងដោយ RAC សម្រាប់ប្រភេទនីតិបុគ្គល ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់។ វិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងត្រូវធ្វើឡើងប្រកបដោយសង្គតិភាព។

១.៦ RAC ត្រូវកំណត់ពីនិយមន័យនៃមាត្រដ្ឋានវាយតម្លៃចំណាត់ថ្នាក់នីមួយៗ និងត្រូវអនុវត្តប្រកបដោយសង្គតិភាពសម្រាប់ដំណើរការនៃការវាយតម្លៃទាំងមូលចំពោះបុគ្គលរងចំណាត់ថ្នាក់ និងឧបករណ៍បំណុលរងចំណាត់ថ្នាក់។

១.៧ ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ត្រូវរៀបចំឡើងដោយ RAC ក្នុងនាមក្រុមហ៊ុន (ដោយមិនមែនជាអ្នកវិភាគណាមួយ ឬបុគ្គលិកណាមួយរបស់ RAC ឡើយ។

១.៨ RAC ត្រូវចាត់តាំងអ្នកវិភាគណាមួយ ឬជាក្រុម (ករណីគណៈកម្មាធិការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងត្រូវបានប្រើប្រាស់) ដែលមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការវាយតម្លៃទៅលើលទ្ធភាពសងរបស់បុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់។

១.៩ RAC ត្រូវរក្សាកំណត់ត្រាផ្ទៃក្នុងដែលមានភាពត្រឹមត្រូវ និងមានលក្ខណៈលម្អិតគ្រប់គ្រាន់ដើម្បីបង្កើតដំណើរការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងឡើងវិញចំពោះសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលបានផ្តល់ឱ្យណាមួយ។ កំណត់ត្រាត្រូវបានរក្សាទុក ករណីមានការចាំបាច់ណាមួយដើម្បីបង្កើននូវសុចរឹតភាពនៃដំណើរការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង រួមទាំង ការអនុញ្ញាតឱ្យមុខងារសវនកម្មផ្ទៃក្នុង មុខងារអនុលោមភាព និងមុខងារត្រួតពិនិត្យគុណភាព អាចពិនិត្យនូវសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងកន្លងមក ដើម្បីអនុវត្តតាមទំនួលខុសត្រូវផ្សេងៗគ្នានៃមុខងារទាំងនោះ។ បន្ថែមពីនេះ RAC ត្រូវបង្កើត រក្សា ចងក្រងទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលបានរៀបចំឡើងដើម្បីធានាថាបុគ្គលិករបស់ខ្លួនអនុវត្តការងារដោយគោរពតាមលក្ខខណ្ឌតម្រូវនៃការថែទាំ និងការរក្សាទុក កំណត់ត្រាផ្ទៃក្នុងដែលបានរៀបចំឡើងដោយ RAC ដែលស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

១.១០ RAC ត្រូវបង្កើត រក្សា ចងក្រងទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលបានរៀបចំឡើងដើម្បីជៀសវាងការចេញនូវការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ការវិភាគ ឬរបាយការណ៍ ដែលមានការបកស្រាយខុស ឬនាំឱ្យមានការយល់ខុស ទៅលើលទ្ធភាពសងនៃបុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់។

១.១១ RAC ត្រូវធានាថាមានធនធានគ្រប់គ្រាន់ ដើម្បីអនុវត្ត និងរក្សាឱ្យបាននូវការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងក្នុងកម្រិតគុណភាពខ្ពស់។ នៅពេលសម្រេចថាចេញនូវចំណាត់ថ្នាក់លទ្ធភាពសងចំពោះបុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់ RAC ត្រូវធ្វើការវាយតម្លៃពីភាពគ្រប់គ្រាន់នៃចំនួនអ្នកវិភាគដែលមានជំនាញជាក់លាក់ និងភាពគ្រប់គ្រាន់នៃព័ត៌មាន ព្រមទាំងលទ្ធភាពក្នុងការទទួលបានព័ត៌មានទាំងនោះដោយអ្នកវិភាគ ដើម្បីធ្វើការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងក្នុងកម្រិតគុណភាពខ្ពស់។

១.១២ RAC ត្រូវបង្កើត និងរក្សាមុខងារត្រួតពិនិត្យដែលបង្កើតឡើងដោយអ្នកគ្រប់គ្រងជាន់ខ្ពស់មួយរូប ឬច្រើននាក់ដែលមានបទពិសោធន៍សមស្របក្នុងការពិនិត្យលើលទ្ធភាពនៃការផ្តល់ចំណាត់ថ្នាក់លទ្ធភាពសងចំពោះបុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់ដែលមានលក្ខ

ណៈខុសពីបុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលរងចំណាត់ថ្នាក់ដែល RAC កំពុងធ្វើការវាយតម្លៃនាពេលបច្ចុប្បន្ន។

១.១៣ RAC ត្រូវបង្កើត និងរក្សាមុខងារត្រួតពិនិត្យដែលរៀបចំឡើងដោយអ្នកគ្រប់គ្រងជាន់ខ្ពស់មួយរូប ឬច្រើននាក់ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យដោយម៉ត់ចត់ មានលក្ខណៈផ្លូវការ និងជាប្រចាំដោយអនុលោមតាមកាលវិភាគដែលបានកំណត់ ទិដ្ឋភាពទាំងអស់នៃវិធីសាស្រ្តវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC (រួមទាំងគំរូ និងការសន្មត់សំខាន់ៗ) និងការផ្លាស់ប្តូរសំខាន់ណាមួយចំពោះវិធីសាស្រ្តវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង។ ឧទាហរណ៍៖ RAC ត្រូវវាយតម្លៃលើវិធីសាស្រ្តនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលមានស្រាប់ និងគំរូនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងទៅលើផលិតផលហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញឱ្យបានសមស្រប នៅពេលដែលលក្ខណៈហានិភ័យរបស់ទ្រព្យសកម្មដើមនៃផលិតផលហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញនោះមានការផ្លាស់ប្តូរជាសំខាន់ណាមួយ។
បុគ្គលិកដែលទទួលខុសត្រូវអនុវត្តដំណើរការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ត្រូវបំពេញមុខងារនេះប្រកបដោយភាពឯករាជ្យ ដោយផ្អែកលើលទ្ធភាព និងភាពសមស្រប នៃទំហំ និងវិសាលភាពនៃអាជីវកម្មវាយតម្លៃលទ្ធភាពសង។

១.១៤ សម្រាប់ការជ្រើសរើសអ្នកវិភាគដែលនឹងត្រូវចូលរួមក្នុងក្នុងដំណើរកាវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង RAC ត្រូវធ្វើការលើកកម្ពស់ដល់ដំណើរការដែលមានលក្ខណៈនិរន្តរភាព ប៉ុន្តែត្រូវចៀសវាងនូវភាពលំអៀងណាមួយដែលអាចកើតឡើងផងដែរ។ ឧទាហរណ៍៖ ក្នុងការធ្វើឱ្យមានតុល្យភាពរវាងគោលបំណងនៃដំណើរការដែលមានលក្ខណៈនិរន្តរភាព និងការចៀសវាងនូវភាពលំអៀងណាមួយដែលអាចកើតឡើង RAC អាចធ្វើការចាត់តាំងក្រុមអ្នកវិភាគដើម្បីចូលរួមក្នុងដំណើរការនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ដោយក្នុងនោះបុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់ត្រូវស្ថិតក្រោមការទទួលខុសត្រូវជាចម្បងនៃការវិភាគរបស់ពួកគេ។

១.១៥ RAC ត្រូវធានាថាបុគ្គលិក និងធនធានហិរញ្ញវត្ថុត្រូវបានបែងចែកគ្រប់គ្រាន់សម្រាប់ធ្វើការត្រួតពិនិត្យ និងធ្វើបច្ចុប្បន្នភាពទៅលើការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងទាំងអស់។ នៅពេលដែលការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងត្រូវបានចេញផ្សាយ លើកលែងចំពោះការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលមិនតម្រូវឱ្យមានការតាមដានបន្ត ក្នុងនោះ RAC ត្រូវធ្វើការត្រួតពិនិត្យការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងតាមគោលការណ៍និរន្តរភាព ដូចខាងក្រោម៖

ក-ត្រួតពិនិត្យលើលទ្ធភាពសងរបស់បុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់ឱ្យបានទៀងទាត់

ខ-បង្កើតឱ្យមាននូវកម្រិតនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនៅពេលទទួលបានព័ត៌មានសមស្របណាមួយដែលអាចរំពឹងទុកថានឹងមានសកម្មភាពនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង

(រាប់បញ្ចូលទាំង ការដកនូវចំណាត់ថ្នាក់លទ្ធភាពសង) ដែលស្របទៅតាមវិធីសាស្ត្រនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង

គ-ត្រួតពិនិត្យលើផលប៉ះពាល់ និងធ្វើការកែប្រែនូវវិធីសាស្ត្រនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង គំរូ ឬការសន្មត់សំខាន់ៗណាមួយទៅលើចំណាត់ថ្នាក់លទ្ធភាពសងដែលពាក់ព័ន្ធ ក្នុងរយៈពេលសមស្របណាមួយ

ឃ-ធ្វើបច្ចុប្បន្នភាពជាប្រចាំទៅលើចំណាត់ថ្នាក់លទ្ធភាពសងឱ្យបានសមស្រប ដោយផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ និង

ង-ការរួមបញ្ចូលនូវបទពិសោធន៍ទាំងអស់ដែលទទួលបាន។

១.១៦ ករណី RAC ប្រើប្រាស់ក្រុមនៃអ្នកវិភាគដាច់ដោយឡែកសម្រាប់ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងជាលើកដំបូង និងសម្រាប់ការត្រួតពិនិត្យជាបន្តបន្ទាប់នៃចំណាត់ថ្នាក់លទ្ធភាពសងដែលមានស្រាប់ ក្រុមនីមួយៗត្រូវមានកម្រិតជំនាញ និងធនធានគ្រប់គ្រាន់ដែលចាំបាច់ដើម្បីអនុវត្តមុខងាររៀងៗខ្លួនឱ្យបានទាន់ពេលវេលា។

១.១៧ RAC ត្រូវបង្កើត រក្សា ចងក្រងទុកជាឯកសារ និងអនុវត្តគោលនយោបាយ និងនីតិវិធីដែលកំណត់យ៉ាងច្បាស់នូវគោលការណ៍ណែនាំសម្រាប់ការផ្សព្វផ្សាយចំណាត់ថ្នាក់លទ្ធភាពសងដែលជាលទ្ធផល ឬជាកម្មវត្ថុនៃសកម្មភាពនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង និងរបាយការណ៍ដែលពាក់ព័ន្ធ និងនៅពេលដែលចំណាត់ថ្នាក់លទ្ធភាពសងត្រូវបានដកចេញ។

### ក-សុចរិតភាពនៃដំណើរការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង

១.១៨ RAC និងនិយោជិតរបស់ខ្លួនត្រូវដោះស្រាយដោយស្មើភាព និងស្មោះត្រង់ជាមួយបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) អ្នកដឹកនាំដំណើរការបោះផ្សាយ (originators) ក្រុមហ៊ុនធានាទិញ ក្រុមអ្នកធានាទិញ (arrangers) និងអ្នកប្រើប្រាស់ចំណាត់ថ្នាក់លទ្ធភាពសង។

១.១៩ បុគ្គលិករបស់ RAC ត្រូវប្រកាន់ខ្ជាប់នូវស្តង់ដាសុចរិតភាពក្នុងកម្រិតខ្ពស់មួយ និងត្រូវមានអាកប្បកិរិយាប្រកបដោយក្រមសីលធម៌ ព្រមជាមួយគ្នានេះដែរ RAC ត្រូវមានគោលនយោបាយ និងនីតិវិធីដែលត្រូវបានរៀបចំឡើងដើម្បីធានាថាមិនមានបុគ្គលិកណាមួយត្រូវបានបង្ហាញថាធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនោះឡើយ។

១.២០ RAC និងបុគ្គលិករបស់ខ្លួនមិនត្រូវផ្តល់ការធានាណាមួយដោយផ្ទាល់ ឬប្រយោលដល់បុគ្គលរងចំណាត់ថ្នាក់, បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors), អ្នកដឹកនាំដំណើរការបោះផ្សាយ (originators), ក្រុមហ៊ុនធានាទិញ, ក្រុមអ្នកធានាទិញ (arrangers) និងអ្នកប្រើប្រាស់ចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC អំពីលទ្ធផលជាក់លាក់ណាមួយនៃសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនោះឡើយ។ ការណ៍នេះមិនបានធ្វើឱ្យរាំងស្ទះក្នុងការបង្កើតនូវសូចនាករបឋមដែលមានលក្ខណៈ

ស្របតាមចំណុចទី **១.២២** និង **២.៦ (ឃ)** នៃក្រមសីលធម៌វិជ្ជាជីវៈរបស់ RAC ក្នុងពេលបច្ចុប្បន្ននោះឡើយ។

**១.២១** RAC និងបុគ្គលិករបស់ខ្លួននឹងមិនត្រូវធ្វើការសន្យា ឬការគម្រាមកំហែងណាមួយអំពីសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងសក្តានុពលណាមួយដើម្បីធ្វើឱ្យមានឥទ្ធិពលដល់បុគ្គលរងចំណាត់ថ្នាក់, បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors), អ្នកដឹកនាំដំណើរការបោះផ្សាយ (originators), ក្រុមហ៊ុនជានាទិញ, ក្រុមអ្នកជានាទិញ (arrangers) និងអ្នកប្រើប្រាស់ចំណាត់ថ្នាក់លទ្ធភាពសងរបស់ របស់ RAC (ឧទា. អ្នកធ្វើបរិវិសកម្ម) ដើម្បីទូទាត់សម្រាប់សេវាវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ឬសេវាកម្មផ្សេងទៀតនោះឡើយ។

**១.២២** RAC និងបុគ្គលិករបស់ខ្លួនមិនត្រូវបង្កើតសំណើ ឬអនុសាសន៍ទាក់ទងនឹងសកម្មភាពរបស់បុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុលដែលអាចជះឥទ្ធិពលដល់ចំណាត់ថ្នាក់លទ្ធភាពសងរបស់បុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុល ដោយរួមបញ្ចូលនូវសំណើ ឬអនុសាសន៍អំពីរចនាសម្ព័ន្ធផ្នែកច្បាប់ ទ្រព្យសកម្មនិងបំណុល ប្រតិបត្តិការធុរកិច្ច ផែនការវិនិយោគ សំណុំនៃហិរញ្ញប្បទាន ការរួមបញ្ចូលគ្នានៃធុរកិច្ច និងការបង្កើតនូវផលិតផលហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញនោះឡើយ។

**១.២៣** នៅក្នុងយុត្តាធិការនីមួយៗដែល RAC ធ្វើប្រតិបត្តិការអាជីវកម្ម RAC ត្រូវបង្កើត រក្សា ចងក្រងទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលបានរៀបចំឡើងដើម្បីធានាថា RAC និងនិយោជិតរបស់ខ្លួនគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក. RAC ត្រូវបង្កើតមុខងារអនុលោមភាពដែលទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យលើអនុលោមភាពរបស់ RAC និងបុគ្គលិករបស់ខ្លួន ជាមួយនឹងបញ្ញត្តិដែលមាននៅក្នុងក្រមសីលធម៌វិជ្ជាជីវៈរបស់ RAC ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ខ. មុខងារអនុលោមភាពត្រូវទទួលខុសត្រូវផងដែរក្នុងការត្រួតពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់នៃគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យរបស់ RAC ដែលត្រូវបានរៀបចំឡើងដើម្បីធានាថាមានអនុលោមភាពតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ RAC ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

គ. RAC ត្រូវចាត់តាំងបុគ្គលិកជាន់ខ្ពស់ដែលមានជំនាញច្បាស់លាស់ដើម្បីបម្រើការជាបុគ្គលិកអនុលោមភាពរបស់ RAC ក្នុងការទទួលបន្ទុកលើមុខងារអនុលោមភាព។ របាយការណ៍ និងសំណងរបស់បុគ្គលិកអនុលោមភាពត្រូវមានឯករាជ្យភាពពីប្រតិបត្តិការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC ។

**១.២៤** ករណីដឹងថា មាននិយោជិតដទៃទៀត ឬសមាការីរបស់ RAC ជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើខុសច្បាប់ អសីលធម៌ ឬផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ RAC បុគ្គលិករបស់ RAC ត្រូវរាយការណ៍ពី

ព័ត៌មាននោះភ្លាមៗទៅបុគ្គលិកអនុលោមភាព ឬបុគ្គលិករបស់ RAC ផ្សេងទៀត ដើម្បីចាត់វិធានការសមស្របណាមួយទៅលើករណីនេះ។ បុគ្គលិករបស់ RAC មិនតម្រូវឱ្យជាអ្នកជំនាញផ្នែកច្បាប់នោះទេ។ ប៉ុន្តែ បុគ្គលិករបស់ RAC ត្រូវរាយការណ៍ទៅកាន់បុគ្គលដែលសាកសមនូវសកម្មភាពដែលអាចចោទជាសំណួរបាន។ បន្ទាប់ពីទទួលបានការរាយការណ៍ពីបុគ្គលិកនោះ RAC មានកាតព្វកិច្ចក្នុងការចាត់វិធានការសមស្រប ដូចដែលបានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិនៅក្នុងយុត្តាធិការនោះ និងគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលបានបង្កើតឡើង រក្សាទុក ចងក្រងទុកជាឯកសារ និងអនុវត្តដោយ RAC ។ RAC ត្រូវហាមឃាត់នូវការឆ្លើយបែបអវិជ្ជមានណាមួយដែលធ្វើឡើងដោយ RAC ឬបុគ្គលិកណាមួយ ចំពោះបុគ្គលិកដែលបានធ្វើការរាយការណ៍នោះ។

## ២. ឯករាជ្យភាពរបស់ RAC និងការចៀសវាងនូវទំនាស់ផលប្រយោជន៍

### ក. ទិដ្ឋភាពទូទៅ

២.១ RAC មិនត្រូវពន្យារពេល ឬបញ្ឈប់សកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដោយផ្អែកលើឥទ្ធិពលដែលមានសក្តានុពល (សេដ្ឋកិច្ច នយោបាយ ឬកត្តាផ្សេងទៀត) នៃសកម្មភាពលើ RAC បុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) អ្នកដឹកនាំដំណើរការបោះផ្សាយ (originators) ក្រុមហ៊ុនជានាទិញ ក្រុមអ្នកជានាទិញ (arrangers) វិនិយោគិន ឬអ្នកចូលរួមទីផ្សារដទៃទៀតនោះឡើយ។

២.២ RAC និងបុគ្គលិករបស់ខ្លួនត្រូវធ្វើការវិនិច្ឆ័យដោយយកចិត្តទុកដាក់ និងប្រកបដោយវិជ្ជាជីវៈ ដើម្បីរក្សាឱ្យបាននូវឯករាជ្យភាព និងភាពច្បាស់លាស់របស់ RAC និងបុគ្គលិករបស់ខ្លួន។

២.៣ ការប្តេជ្ញាចិត្តរបស់ RAC លើការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងត្រូវទទួលរងឥទ្ធិពលដោយកត្តាដែលពាក់ព័ន្ធនឹងការវាយតម្លៃលទ្ធភាពសងនៃបុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់ តែប៉ុណ្ណោះ។

២.៤ ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលធ្វើឡើងដោយ RAC ចំពោះបុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់ មិនត្រូវទទួលរងឥទ្ធិពលពីទំនាក់ទំនងអាជីវកម្មដែលមានស្រាប់ ឬសក្តានុពលណាមួយរវាង RAC (ឬសមាការីរបស់ខ្លួន) និងបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) អ្នកដឹកនាំដំណើរការបោះផ្សាយ (originators) ក្រុមហ៊ុនជានាទិញ ក្រុមអ្នកជានាទិញ (arrangers) (ឬសមាការីរបស់ពួកគេ) ឬភាគីណាមួយផ្សេងទៀតឡើយ។

២.៥ RAC ត្រូវធ្វើការញែកឱ្យដាច់រវាងផ្នែកប្រតិបត្តិការ ផ្នែកច្បាប់ និងផ្នែករូបវន្ត (ប្រសិនមាន) នូវអាជីវកម្មវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង និងអ្នកវិភាគរបស់ខ្លួនជាមួយនឹងអាជីវកម្មដទៃទៀតដែលអាចនាំឱ្យមានទំនាស់ផលប្រយោជន៍ណាមួយកើតឡើង។ សម្រាប់អាជីវកម្មផ្សេងទៀតដែលមិនមានទំនាស់ផលប្រយោជន៍ RAC ត្រូវបង្កើត រក្សាទុក ចងក្រងទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលត្រូវរៀបចំឡើងដើម្បីកាត់បន្ថយលទ្ធភាពដែលអាចនាំឱ្យមានទំនាស់ផលប្រយោជន៍នឹងកើតឡើង។ RAC ត្រូវបង្ហាញពីមូលហេតុសមស្របណាមួយដែលពាក់ព័ន្ធនឹងអាជីវកម្មផ្សេងទៀតដែលមិនមានទំនាស់ប្រយោជន៍ជាមួយអាជីវកម្មវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ខ្លួននោះ។

### ខ.គោលនយោបាយ នីតិវិធី ការគ្រប់គ្រង និងការបង្ហាញព័ត៌មានរបស់ RAC

២.៦ RAC ត្រូវបង្កើត រក្សាទុក ចងក្រងទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដើម្បីកំណត់ និងលុបបំបាត់ ឬគ្រប់គ្រង និងបង្ហាញព័ត៌មាននូវទំនាស់ផលប្រយោជន៍ជាក់ស្តែង

ឬទំនាស់ផលប្រយោជន៍សក្តានុពលណាមួយដែលអាចជះឥទ្ធិពលដល់វិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង សកម្មភាពនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ឬការវិភាគរបស់ RAC ឬការវិនិច្ឆ័យ និងការវិភាគរបស់បុគ្គលិក RAC ។ ក្នុងចំណោមនោះដែរ គោលនយោបាយ នីតិវិធី និងការគ្រប់គ្រងត្រូវលើកឡើង (ដូចដែលអនុវត្តចំពោះគំរូអាជីវកម្មរបស់ RAC) ពីរបៀបដែលទំនាស់ដូចមានខាងក្រោមដែលអាចមានឥទ្ធិពលលើវិធីសាស្ត្រនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់RACឬសកម្មភាពនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង៖

ក. ត្រូវបានទូទាត់ដើម្បីការចេញចំណាត់ថ្នាក់លទ្ធភាពសងដោយបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) អ្នកដឹកនាំដំណើរការបោះផ្សាយ (originators) ក្រុមហ៊ុនជានាទិញ ក្រុមអ្នកជានាទិញ (arrangers) នៃឧបករណ៍បំណុលដែលរងចំណាត់ថ្នាក់។

ខ. ត្រូវបានទូទាត់ដោយអ្នកធ្វើបរិវិសកម្មជាមួយនឹងអត្ថប្រយោជន៍ហិរញ្ញវត្ថុដែលអាចទទួលរងឥទ្ធិពលដោយសកម្មភាពនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC

គ. ត្រូវបានទូទាត់ដោយបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) អ្នកដឹកនាំដំណើរការបោះផ្សាយ (originators) ក្រុមហ៊ុនជានាទិញ ក្រុមអ្នកជានាទិញ (arrangers) ឬអ្នកធ្វើបរិវិសកម្ម ដែលក្រៅពីសេវាកម្មវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ឬផ្តល់ការអនុញ្ញាតឱ្យទទួលបានព័ត៌មានណាមួយពាក់ព័ន្ធនឹងការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC។

ឃ. ការផ្តល់នូវសូចនាករនៃគុណភាពលទ្ធភាពសងជាបឋមឬដែលមានលក្ខណៈស្រដៀងគ្នា ដល់បុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) អ្នកដឹកនាំដំណើរការបោះផ្សាយ (originators) ក្រុមហ៊ុនជានាទិញ ក្រុមអ្នកជានាទិញ (arrangers) និង

ង. មានផលប្រយោជន៍ជាលក្ខណៈកម្មសិទ្ធិដោយផ្ទាល់ ឬប្រយោលនៅក្នុងអង្គភាពរបស់បុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) ឬមានបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) មានផលប្រយោជន៍កម្មសិទ្ធិដោយផ្ទាល់ ឬប្រយោលនៅក្នុង RAC។

**២.៧** RAC ត្រូវបង្ហាញទំនាស់ផលប្រយោជន៍ជាក់ស្តែង និងទំនាស់ផលប្រយោជន៍សក្តានុពល (រួមទាំង ទំនាស់ផលប្រយោជន៍ដែលមានកំណត់ក្នុងគោលការណ៍ ២.៦ ខាងលើ) ឱ្យបានពេញលេញ ទាន់ពេលវេលា ច្បាស់លាស់ រឹងមាំ ជាក់លាក់ និងសំខាន់។ នៅពេលដែលទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬទំនាស់ផលប្រយោជន៍សក្តានុពលមានលក្ខណៈដាច់ដោយឡែក ឬជាក់លាក់ណាមួយចំពោះសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងទាក់ទងនឹងបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល (obligors) អ្នកដឹកនាំដំណើរការបោះផ្សាយ (originators) ក្រុមហ៊ុនជានាទិញ ក្រុមអ្នកជានាទិញ (arrangers) ឬឧបករណ៍បំណុលណាមួយ ទំនាស់ផលយោជន៍នោះត្រូវបង្ហាញក្នុងទម្រង់ដូចគ្នា និងតាមរយៈមធ្យោបាយដូចគ្នានឹងសកម្មភាពវាយតម្លៃលទ្ធភាពសងដែលពាក់ព័ន្ធ។

២.៨ RAC ត្រូវបង្ហាញព័ត៌មានពាក់ព័ន្ធនឹងទិដ្ឋភាពទូទៅនៃការទូទាត់ថ្លៃសេវាវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងជាមួយនឹងបុគ្គលរងចំណាត់ថ្នាក់, បុគ្គលជាប់កាតព្វកិច្ចបំណុល, ក្រុមហ៊ុនជានាទិញ ឬក្រុមអ្នកជានាទិញ (arrangers)

ក. នៅពេលដែល RAC ទទួលបានការទូទាត់ណាមួយក្រៅពីការទូទាត់ថ្លៃសេវាវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងពីអង្គភាពវាយតម្លៃ កាតព្វកិច្ច អ្នកដឹកនាំដំណើរការបោះផ្សាយ អ្នកជានាទិញ RAC ត្រូវបង្ហាញសំណងដែលមិនពាក់ព័ន្ធនោះក្នុងទម្រង់ជាភាគរយនៃសំណងប្រចាំឆ្នាំសរុបដែលទទួលបានពីបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល ក្រុមហ៊ុនជានាទិញ ឬក្រុមអ្នកជានាទិញ (arrangers) នៅក្នុងរបាយការណ៍វាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ឬឯកសារផ្សេងទៀត។

ខ. RAC ត្រូវបង្ហាញព័ត៌មាននៅក្នុងរបាយការណ៍វាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ឬឯកសារផ្សេងទៀត ករណីទទួលបានចំណូលប្រចាំឆ្នាំ ១០ (ដប់) ភាគរយ ឬលើសពី ១០ (ដប់) ភាគរយ ពីអតិថិជនតែមួយ (ឧទាហរណ៍៖ បុគ្គលរងចំណាត់ថ្នាក់, បុគ្គលជាប់កាតព្វកិច្ចបំណុល, ក្រុមហ៊ុនជានាទិញ ឬក្រុមអ្នកជានាទិញ (arrangers) ឬ អ្នកធ្វើបរិវិសកម្ម ឬសមាការីណាមួយរបស់ពួកគេ)

២.៩ RAC ត្រូវបង្ហាញព័ត៌មាននៅក្នុងសេចក្តីប្រកាសព័ត៌មានស្តីពីការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ខ្លួនថា ក្រុមហ៊ុនបោះផ្សាយនៃផលិតផលហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញបានជូនដំណឹងដល់ RAC នូវព័ត៌មានពាក់ព័ន្ធទាំងអស់អំពីឧបករណ៍បំណុលដែលត្រូវបានវាយតម្លៃ ថាតើត្រូវផ្សព្វផ្សាយជាសាធារណៈ ឬមិនត្រូវបង្ហាញជាសាធារណៈ។

២.១០ RAC មិនត្រូវកាន់កាប់ ឬធ្វើប្រតិបត្តិការក្នុងឧបករណ៍ជួញដូរដែលមានទំនាស់ផលប្រយោជន៍ជាមួយសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC ឡើយ។

២.១១ ករណីបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល (ឧ. ប្រទេស ឬរដ្ឋអធិបតេយ្យ) បាន ឬកំពុងបន្តអនុវត្តមុខងារត្រួតពិនិត្យដែលទាក់ទងនឹង RAC ក្នុងពេលដំណាលគ្នា បុគ្គលិកដែលទទួលខុសត្រូវក្នុងការប្រាស្រ័យទាក់ទងជាមួយបុគ្គលិករបស់បុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល (ឧ. និយ័តករ) ទាក់ទងនឹងបញ្ហាត្រួតពិនិត្យ គឺត្រូវញែកឱ្យដាច់ពីបុគ្គលិកដែលចូលរួមក្នុងសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ឬបង្កើត ឬកែប្រែវិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ដែលអនុវត្តចំពោះបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុលនោះ។

**គ. ឯករាជ្យភាពរបស់បុគ្គលិក RAC**

២.១២ ប្រកនៃការរាយការណ៍របស់បុគ្គលិក RAC និងការទូទាត់សំណងត្រូវរៀបចំឡើងដើម្បីលុបបំបាត់ ឬគ្រប់គ្រងទំនាស់ផលប្រយោជន៍ដែលកំពុងកើតមាន និងទំនាស់ផលប្រយោជន៍ដែលអាចកើតឡើងនាពេលអនាគតប្រកបដោយប្រសិទ្ធភាព។

ក. បុគ្គលិករបស់ RAC ដែលចូលរួម ឬដែលអាចមានឥទ្ធិពលលើសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់អង្គភាព ឬឧបករណ៍បំណុលណាមួយ មិនត្រូវបានផ្តល់សំណង ឬវាយតម្លៃដោយផ្អែកលើទំហំប្រាក់ចំណូលដែល RAC ទទួលបានពីបុគ្គលរងចំណាត់ថ្នាក់ ឬអ្នកជាប់បំណុលនោះឡើយ។

ខ. RAC ត្រូវធ្វើការត្រួតពិនិត្យជាផ្លូវការ និងតាមកាលកំណត់នូវគោលនយោបាយ នីតិវិធី និងការអនុវត្តលើការទូទាត់សំណងរបស់ខ្លួនសម្រាប់បុគ្គលិក RAC ដែលចូលរួម ឬអ្នកដែលអាចមានឥទ្ធិពលលើសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដើម្បីធានាថាគោលនយោបាយ នីតិវិធី និងការអនុវត្តទាំងនោះមិនមានការសម្របសម្រួលណាមួយ និងមិនធ្វើឱ្យប៉ះពាល់ដល់ភាពច្បាស់លាស់នៃដំណើរការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC នោះឡើយ។

**២.១៣** បុគ្គលិករបស់ RAC ដែលចូលរួម ឬអ្នកដែលអាចនឹងមានឥទ្ធិពលលើសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង មិនត្រូវចាប់ផ្តើម ឬចូលរួមក្នុងការពិភាក្សាជាមួយបុគ្គលរងចំណាត់ថ្នាក់ អ្នកជាប់កាតព្វកិច្ចបំណុល ក្រុមអ្នកធានាទិញ ឬអ្នកធ្វើបរិវិសកម្ម ពាក់ព័ន្ធនឹងថ្លៃសេវា ឬការទូទាត់ដែលគិតទៅលើបុគ្គលរងចំណាត់ថ្នាក់ អ្នកជាប់កាតព្វកិច្ចបំណុល ក្រុមអ្នកធានាទិញ ឬអ្នកធ្វើបរិវិសកម្មនោះឡើយ។

**២.១៤** បុគ្គលិករបស់ RAC មិនត្រូវចូលរួម ឬធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC ទៅលើបុគ្គលរងចំណាត់ថ្នាក់ ឬឧបករណ៍បំណុល ប្រសិនបើបុគ្គលិក សមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក (ឧទាហរណ៍ ប្តី/ប្រពន្ធ ដៃគូក្នុងស្រុក ឬអ្នកនៅក្នុងបន្ទុក) ឬអង្គភាពនោះ ត្រូវបានគ្រប់គ្រងដោយបុគ្គលិកនោះឡើយ (ឧ. បរធនបាល)

ក. កាន់កាប់ ឬធ្វើប្រតិបត្តិការនៅក្នុងឧបករណ៍ជួញដូរដែលបោះផ្សាយដោយបុគ្គលរងចំណាត់ថ្នាក់ ឬអ្នកជាប់បំណុល

ខ. កាន់កាប់ ឬធ្វើប្រតិបត្តិការឧបករណ៍ជួញដូរ (ក្រៅពីគម្រោងវិនិយោគរួម) ដែលមានអត្ថប្រយោជន៍លើបុគ្គលរងចំណាតថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល ឬជាឧបករណ៍និស្សន្ទដែលផ្អែកលើឧបករណ៍ជួញដូរដែលចេញដោយបុគ្គលរងចំណាតថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល។

គ. កាន់កាប់ ឬធ្វើប្រតិបត្តិការនៅក្នុងឧបករណ៍ជួញដូរដែលបោះផ្សាយដោយសមាការីនៃ បុគ្គលរងចំណាតថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល ដែលភាពជាម្ចាស់កម្មសិទ្ធិនេះអាចបណ្តាលឱ្យមានទំនាស់ផលប្រយោជន៍ទាក់ទងនឹងបុគ្គលិក ឬ RAC។

ឃ. កាន់កាប់ ឬធ្វើប្រតិបត្តិការនៅក្នុងឧបករណ៍ជួញដូរដែលបោះផ្សាយដោយក្រុមហ៊ុនធានាទិញ ក្រុមអ្នកធានាទិញនៃបុគ្គលរងចំណាត់ថ្នាក់ ដែលភាពជាម្ចាស់កម្មសិទ្ធិនោះអាចបណ្តាលឱ្យមានទំនាស់ផលប្រយោជន៍ដល់បុគ្គលិក ឬ RAC។

ង. ត្រូវបានជួល ឬមានទំនាក់ទំនងការងារ ឬទំនាក់ទំនងអាជីវកម្មសំខាន់ៗផ្សេងទៀតជាមួយបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល ឬក្រុមហ៊ុនជានាទិញ ក្រុមអ្នកជានាទិញនៃបុគ្គលរងចំណាត់ថ្នាក់ដែលអាចបណ្តាលឱ្យមានទំនាស់ផលប្រយោជន៍។

ច. គឺជាអភិបាលរបស់បុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ច ឬក្រុមហ៊ុនជានាទិញ ឬក្រុមអ្នកជានាទិញនៃបុគ្គលរងចំណាត់ថ្នាក់

ឆ. មាន ឬធ្លាប់មានទំនាក់ទំនង ឬអត្ថប្រយោជន៍ផ្សេងទៀតជាមួយបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ច ឬក្រុមហ៊ុនជានាទិញ ឬក្រុមអ្នកជានាទិញនៃបុគ្គលរងចំណាត់ថ្នាក់ (ឬសមាការីណាមួយរបស់ពួកគេ) ដែលអាចបណ្តាលឱ្យមានទំនាស់ផលប្រយោជន៍។

**២.១៥** អ្នកវិភាគរបស់ RAC មិនត្រូវកាន់កាប់ ឬធ្វើប្រតិបត្តិការនៅក្នុងឧបករណ៍ជួញដូរដែលបោះផ្សាយដោយបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុលនៅក្នុងដែនទំនួលខុសត្រូវចម្បងរបស់អ្នកវិភាគនោះទេ។ ការណ៍នេះនឹងមិនរារាំងអ្នកវិភាគពីការកាន់កាប់ ឬការជួញដូរគម្រោងវិនិយោគរួមដែលធ្វើការវិនិយោគលើឧបករណ៍ជួញដូរដែលបោះផ្សាយដោយបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុលនៅក្នុងដែនទំនួលខុសត្រូវចម្បងរបស់អ្នកវិភាគនោះទេ។

**២.១៦** បុគ្គលិករបស់ RAC ត្រូវហាមឃាត់មិនឱ្យស្វែងរកប្រាក់ អំណោយ ឬការអនុគ្រោះពីបុគ្គលណាម្នាក់ដែល RAC ធ្វើអាជីវកម្មជាមួយ ហើយត្រូវហាមឃាត់មិនឱ្យទទួលយកអំណោយដែលផ្តល់ជូនក្នុងទម្រង់ជាសាច់ប្រាក់ ឬសមមូលសាច់ប្រាក់ ឬអំណោយណាមួយដែលលើសពីតម្លៃរូបិយវត្ថុតិចតួច។

**២.១៧** បុគ្គលិករបស់ RAC ដែលមានទំនាក់ទំនងផ្ទាល់ (ឧទាហរណ៍ ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយបុគ្គលិកបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល ឬអ្នកដឹកនាំដំណើរការបោះផ្សាយ ក្រុមហ៊ុនជានាទិញ ឬក្រុមអ្នកជានាទិញនៃបុគ្គលរងចំណាត់ថ្នាក់ ដែលបង្កើតឱ្យមានទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬសក្តានុពលដែលតម្រូវឱ្យស្ថិតក្រោមគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យរបស់ RAC ដើម្បីបង្ហាញទំនាក់ទំនងទៅបុគ្គលិកអនុលោមភាព បុគ្គលិកផ្សេងទៀតរបស់ RAC ឱ្យបានសមស្រប។

**២.១៨** RAC ត្រូវបង្កើត ថែរក្សា រក្សាទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការត្រួតពិនិត្យភ្លាមៗចំពោះការងារកន្លងមករបស់អ្នកវិភាគដែលលាឈប់ RAC ព្រមទាំងចូលរួមការងារនៅក្នុងអង្គភាពរបស់បុគ្គលរងចំណាត់ថ្នាក់ ឬអ្នកជាប់កាតព្វកិច្ចបំណុល និយោជិតបានចូលរួមក្នុងការវាយតម្លៃ ដែលការចូលរួមនេះមានការដោះដូរជាសំខាន់ណាមួយទៅលើភារកិច្ចរបស់ខ្លួននៅ RAC ឬសមាការីណាមួយរបស់ពួកគេ។

### ៣. ទំនួលខុសត្រូវរបស់ RAC ចំពោះការវិនិយោគសាធារណៈ បុគ្គលរងចំណាត់ថ្នាក់ អ្នកដឹកនាំដំណើរការបោះផ្សាយ ក្រុមហ៊ុនជានាទិញ និងក្រុមអ្នកជានាទិញ

### ក. តម្លាភាព និងភាពទាន់ពេលវេលានៃការបង្ហាញការវាយតម្លៃលទ្ធភាពសង

៣.១ RAC ត្រូវជួយវិនិយោគិន និងអ្នកប្រើប្រាស់ចំណាត់ថ្នាក់វាយតម្លៃលទ្ធភាពសងក្នុងការអភិវឌ្ឍការយល់ដឹងកាន់តែច្រើនអំពីចំណាត់ថ្នាក់វាយតម្លៃលទ្ធភាពសង ដោយធ្វើការបង្ហាញជាភាសាសាមញ្ញនូវលក្ខណៈ និងដែនកំណត់នៃចំណាត់ថ្នាក់វាយតម្លៃលទ្ធភាពសង និងហានិភ័យ ដើម្បីសម្រេចចិត្តធ្វើការវិនិយោគ ឬការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុផ្សេងទៀត។ ករណី RAC ជាកម្មវត្ថុនៃការចុះបញ្ជីភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង និងគ្រប់គ្រងដោយអាជ្ញាធរក្នុងតំបន់ ឬថ្នាក់ជាតិនោះ RAC មិនត្រូវធ្វើការបង្ហាញណាមួយថាអាជ្ញាធរបានសម្រេចយល់ព្រមលើការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ឬប្រើប្រាស់ការចុះបញ្ជីនេះដើម្បីផ្សព្វផ្សាយអំពីគុណភាពនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ខ្លួននោះឡើយ។

៣.២ RAC ត្រូវបង្ហាញព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីដំណើរការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង និងវិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ខ្លួន ដើម្បីឱ្យវិនិយោគិន និងអ្នកប្រើប្រាស់ផ្សេងទៀតអាចយល់ពីរបៀបដែលចំណាត់ថ្នាក់លទ្ធភាពសងត្រូវបានកំណត់ដោយ RAC ។

៣.៣ RAC ត្រូវបង្ហាញការកែប្រែសំខាន់ៗចំពោះវិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង មុនពេលការកែប្រែចូលជាធរមាន លុះត្រាតែការធ្វើដូច្នេះនឹងជះឥទ្ធិពលអវិជ្ជមានដល់សុចរិតភាពនៃចំណាត់ថ្នាក់លទ្ធភាពសងដោយការពន្យារពេលហួសហេតុនៃសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង។ ក្នុងករណីណាក៏ដោយ RAC ត្រូវបង្ហាញការកែប្រែសំខាន់ៗក្នុងលក្ខណៈមិនជ្រើសរើស។

៣.៤ RAC ត្រូវង្ហាញពីគោលនយោបាយ និងនីតិវិធីរបស់ខ្លួនដែលលើកឡើងនូវការចេញចំណាត់ថ្នាក់ឥណទានដែលមិនមានការស្នើសុំ។

៣.៥ RAC ត្រូវបង្ហាញគោលនយោបាយ និងនីតិវិធីរបស់ខ្លួនសម្រាប់ការចែកចាយចំណាត់ថ្នាក់លទ្ធភាពសង និងរបាយការណ៍ ហើយសម្រាប់ពេលដែលការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនឹងត្រូវបានដកចេញ។

៣.៦ RAC ត្រូវបង្ហាញនិយមន័យឱ្យបានច្បាស់លាស់នៃអត្ថន័យនៃប្រភេទនីមួយៗនៅក្នុងមាត្រដ្ឋានវាយតម្លៃ រួមទាំងនិយមន័យនៃការមិនទូទាត់សង។

៣.៧ RAC ត្រូវបែងចែកការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនៃផលិតផលហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញ និងការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនៃបុគ្គលរងចំណាត់ថ្នាក់ ឬអ្នកជាប់

កាតព្វកិច្ចបំណុលផ្សេងទៀត តាមរយៈការកំណត់ចំណាត់ថ្នាក់ វាយតម្លៃលទ្ធភាពសងផ្សេងគ្នា។ RAC ត្រូវបង្ហាញពីមុខងារដែលមានលក្ខណៈខុសគ្នានេះ។

៣.៨ RAC ត្រូវមានតម្លាភាពជាមួយវិនិយោគិន បុគ្គលរងចំណាត់ថ្នាក់ អ្នកជាប់កាតព្វកិច្ចបំណុល អ្នកដឹកនាំដំណើរការបោះផ្សាយ ក្រុមហ៊ុនជានាទិញ និងក្រុមអ្នកជានាទិញ អំពីរបៀបវាយតម្លៃ។

៣.៩ ប្រសិនមាន RAC ត្រូវជូនដំណឹងដល់បុគ្គលរងចំណាត់ថ្នាក់ ឬអ្នកជាប់កាតព្វកិច្ចបំណុល ឬក្រុមអ្នកជានាទិញអំពីព័ត៌មានសំខាន់ៗ និងការពិចារណាសំខាន់ៗ ទៅលើចំណាត់ថ្នាក់វាយតម្លៃលទ្ធភាពសងដែលនឹងត្រូវផ្អែកលើ មុនពេលការផ្សព្វផ្សាយចំណាត់ថ្នាក់ឥណទានដែលជាលទ្ធផល ឬកម្មវត្ថុនៃកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង និងផ្តល់ឱកាសគ្រប់គ្រាន់ដល់បុគ្គលរងចំណាត់ថ្នាក់ ឬអ្នកជាប់កាតព្វកិច្ចបំណុល ឬក្រុមអ្នកជានាទិញ កាតព្វកិច្ច ឬអ្នករៀបចំនូវឱកាសគ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីកំហុសជាក់ស្តែង ការលុបចោលណាមួយ ឬការនាំឱ្យយល់ខុសណាមួយដែលនឹងជះឥទ្ធិពលជាសារវន្តលើចំណាត់ថ្នាក់លទ្ធភាពសង។ RAC ត្រូវវាយតម្លៃឱ្យបានត្រឹមត្រូវនូវការឆ្លើយតបណាមួយពីបុគ្គលរងចំណាត់ថ្នាក់ អ្នកជាប់កាតព្វកិច្ចបំណុល ឬអ្នករៀបចំ។ ករណី RAC មិនបានជូនដំណឹងដល់បុគ្គលរងចំណាត់ថ្នាក់ អ្នកជាប់កាតព្វកិច្ចបំណុល ឬអ្នករៀបចំ មុនពេលផ្សព្វផ្សាយសកម្មភាពវាយតម្លៃឥណទាន RAC នឹងជូនដំណឹងដល់បុគ្គលរងចំណាត់ថ្នាក់ អ្នកជាប់កាតព្វកិច្ចបំណុល ឬអ្នករៀបចំឱ្យបានឆាប់តាមដែលជាក់ស្តែងបន្ទាប់ពីនោះ ហើយជាទូទៅត្រូវពន្យល់ពីមូលហេតុដែល RAC មិនបានជូនដំណឹងដល់បុគ្គលរងចំណាត់ថ្នាក់ អ្នកជាប់កាតព្វកិច្ចបំណុល ឬអ្នករៀបចំមុនពេលផ្សព្វផ្សាយសកម្មភាពវាយតម្លៃឥណទាននោះ។

៣.១០ នៅពេលដែល RAC បង្ហាញ ឬចែកចាយជាសាធារណៈដល់អ្នកធ្វើបរិវិសកម្មរបស់ខ្លួន (អាស្រ័យលើគំរូអាជីវកម្មរបស់ RAC) ចំណាត់ថ្នាក់លទ្ធភាពសងដែលជាលទ្ធផល ឬជាកម្មវត្ថុនៃសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង RAC ត្រូវធ្វើការបង្ហាញជូនភ្លាមៗតាមដែលអាចធ្វើបានបន្ទាប់ពីសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងត្រូវបានធ្វើឡើង។

៣.១១ នៅពេលដែល RAC បង្ហាញ ឬចែកចាយជាសាធារណៈដល់អតិថិជនរបស់ខ្លួន (អាស្រ័យលើគំរូអាជីវកម្មរបស់ RAC) ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលជាលទ្ធផល ឬជាកម្មវត្ថុនៃសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង RAC ត្រូវបង្ហាញព័ត៌មានដោយផ្អែកលើមូលដ្ឋានមិនជ្រើសរើស។.

៣.១២ RAC ត្រូវបង្ហាញការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែលជាលទ្ធផល ឬជាកម្មវត្ថុនៃសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងថាតើអង្គភាពវាយតម្លៃ ឧបករណ៍បំណុល ឬអ្នកដឹកនាំដំណើរការបោះផ្សាយ ឬអ្នកជានាទិញលក់ ឬអ្នកប្រើប្រាស់ផ្សេងទៀតបានចូលរួមក្នុងដំណើរការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងដែរ ឬទេ។ ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនីមួយៗដែលមិនត្រូវបាន

ផ្តួចផ្តើមតាមការស្នើសុំរបស់បុគ្គលរងចំណាត់ថ្នាក់ អ្នកជាប់កាតព្វកិច្ចបំណុល ឬអ្នកដឹកនាំដំណើរការបោះផ្សាយ ឬក្រុមហ៊ុនជានាទិញ ឬក្រុមអ្នកជានាទិញត្រូវបានកំណត់អត្តសញ្ញាណ។

៣.១៣ RAC ត្រូវបង្ហាញយ៉ាងច្បាស់អំពីគុណលក្ខណៈ និងដែនកំណត់នៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនីមួយៗ និងវិសាលភាពដែល RAC ផ្ទៀងផ្ទាត់ព័ត៌មានដែលផ្តល់ទៅឱ្យដោយអង្គភាពរងចំណាត់ថ្នាក់ ឧបករណ៍បំណុលរងចំណាត់ថ្នាក់ ឬអ្នកដឹកនាំដំណើរការបោះផ្សាយ ឬអ្នកជានាទិញលក់ ឬអ្នករៀបចំកាតព្វកិច្ចវាយតម្លៃ។ ឧទាហរណ៍ ប្រសិនបើការវាយតម្លៃលទ្ធភាពសងពាក់ព័ន្ធនឹងប្រភេទនៃអង្គភាព ឬឧបករណ៍បំណុលដែលទិន្នន័យប្រវត្តិសាស្ត្រមានកម្រិត RAC ត្រូវបង្ហាញការពិតនេះ និងវិធីសាស្ត្រក្នុងការកំណត់កម្រិតការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង។

៣.១៤ RAC ត្រូវធ្វើការចង្អុលបង្ហាញនៅក្នុងសេចក្តីប្រកាសអំពីការវាយតម្លៃចំណាត់ថ្នាក់ លទ្ធភាពសងដែលកើតចេញពីសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនៅពេលដែលចំណាត់ថ្នាក់លទ្ធភាពសងត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយ ឬពិនិត្យឡើងវិញ។ ការប្រកាសអំពីចំណាត់ ថ្នាក់លទ្ធភាពសងត្រូវបង្ហាញផងដែរនូវវិធីសាស្ត្រវាយតម្លៃលទ្ធភាពសងចម្បង ឬការកែប្រែវិធីសាស្ត្រដែលត្រូវបានប្រើក្នុងការកំណត់ចំណាត់ថ្នាក់លទ្ធភាពសង និងករណីដែលការពិពណ៌នាអំពីវិធីសាស្ត្រវាយតម្លៃណាទានអាចត្រូវបានរកឃើញ។ ករណីការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងផ្អែកលើវិធីសាស្ត្រនៃការផ្តល់ចំណាត់ថ្នាក់លទ្ធភាពសងច្រើនជាងមួយ ឬករណីដែលការពិនិត្យឡើងវិញនូវវិធីសាស្ត្រវាយតម្លៃចំណាត់ថ្នាក់ចម្បងដែលអាចឱ្យវិនិយោគិន និងអ្នកប្រើប្រាស់ផ្សេងទៀតមើលរំលងនូវទិដ្ឋភាពសំខាន់ៗនៃចំណាត់ថ្នាក់លទ្ធភាពសង RAC ត្រូវពន្យល់ករណីនេះនៅក្នុងសេចក្តីប្រកាសអំពីចំណាត់ថ្នាក់លទ្ធភាពសង និងបង្ហាញចំណុចទាំងនោះដើម្បីពិភាក្សាអំពីរបៀបដែលវិធីសាស្ត្រវាយតម្លៃលទ្ធភាពសងខុសៗគ្នា និងទិដ្ឋភាពសំខាន់ៗផ្សេងទៀតអាចពាក់ព័ន្ធនឹងការសម្រេចចិត្តវាយតម្លៃលទ្ធភាពសង។

៣.១៥ នៅពេលវាយតម្លៃផលិតផលហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញ RAC ត្រូវបង្ហាញព័ត៌មានជាសាធារណៈ ឬផ្សព្វផ្សាយជាសាធារណៈដល់អ្នកធ្វើបរិសកម្មរបស់ខ្លួន (អាស្រ័យលើគំរូអាជីវកម្មរបស់ RAC) នូវព័ត៌មានគ្រប់គ្រាន់អំពីការបាត់បង់ និងការវិភាគលំហូរសាច់ប្រាក់ជាមួយនឹងចំណាត់ថ្នាក់លទ្ធភាពសង ដើម្បីឱ្យវិនិយោគិន អ្នកប្រើប្រាស់ផ្សេងទៀតអាចយល់ពីមូលដ្ឋាននៃការកំណត់ចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC ។ RAC ក៏ត្រូវបង្ហាញព័ត៌មានជាសាធារណៈផងដងដែរ ឬផ្សព្វផ្សាយព័ត៌មានអំពីកម្រិតនៃការវិភាគទៅលើចំណុចរសើបនៃការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងនៃផលិតផលហិរញ្ញវត្ថុដែលមានលក្ខណៈស្មុគស្មាញ ដើម្បីផ្លាស់ប្តូរការសន្មត់ដែលផ្អែកលើវិធីសាស្ត្រវាយតម្លៃលទ្ធភាពសងដែលអាចអនុវត្តបាន។

៣.១៦ នៅពេលចេញ ឬកែប្រែការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង RAC ត្រូវពន្យល់នៅក្នុងសេចក្ដីប្រកាសរបស់ខ្លួន និង/ឬរបាយការណ៍ពីការសន្មត់ និងទិន្នន័យសំខាន់ៗដែលផ្អែកលើការវាយតម្លៃលទ្ធភាពសង រួមទាំងការកែតម្រូវរបាយការណ៍ហិរញ្ញវត្ថុ ដែលខុសពីអ្វីដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់បុគ្គលរងចំណាត់ថ្នាក់ដែលពាក់ព័ន្ធ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល។

៣.១៧ ករណី RAC បញ្ឈប់ការតាមដានការវាយតម្លៃលទ្ធភាពសងឱ្យបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល RAC ត្រូវដកការវាយតម្លៃលទ្ធភាពសង ឬបង្ហាញព័ត៌មានពីការបញ្ឈប់នោះជាសាធារណៈ ឬដល់អ្នកធ្វើបរិវិសកម្មរបស់ខ្លួន (អាស្រ័យលើគំរូអាជីវកម្មរបស់ RAC) ភ្លាមៗតាមដែលអាចអនុវត្តបាន។ ចំណាត់ថ្នាក់លទ្ធភាពសងដែលចេញដោយ RAC ដែលលែងត្រូវបានត្រួតពិនិត្យត្រូវបង្ហាញពីកាលបរិច្ឆេទដែលចំណាត់ថ្នាក់លទ្ធភាពសងត្រូវបានធ្វើបច្ចុប្បន្នភាពចុងក្រោយ ឬពិនិត្យឡើងវិញ មូលហេតុដែលចំណាត់ថ្នាក់លទ្ធភាពសងមិនត្រូវបានត្រួតពិនិត្យទៀត ហើយចំណាត់ថ្នាក់ឥណទានលែងត្រូវបានធ្វើបច្ចុប្បន្នភាពទៀតហើយ។

៣.១៨ ដើម្បីលើកកម្ពស់តម្លាភាព និងដើម្បីឱ្យវិនិយោគិន និងអ្នកប្រើប្រាស់ ចំណាត់ថ្នាក់លទ្ធភាពសងផ្សេងទៀតប្រៀបធៀបការអនុវត្តរបស់ភ្នាក់ងារវាយតម្លៃលទ្ធភាពសងផ្សេងៗគ្នា RAC ត្រូវបង្ហាញព័ត៌មានគ្រប់គ្រាន់អំពីការផ្លាស់ប្ដូរជាប្រវត្តិសាស្ត្រ និងអត្រានៃការមិនទូទាត់សងនៃប្រភេទចំណាត់ថ្នាក់លទ្ធភាពសងរបស់ខ្លួន ទាក់ទងទៅនឹងថ្នាក់បុគ្គលរងចំណាត់ថ្នាក់ និងបុគ្គលជាប់កាតព្វកិច្ចបំណុលដែលបានវាយតម្លៃ។ ព័ត៌មាននេះត្រូវរួមបញ្ចូលនូវព័ត៌មានប្រវត្តិសាស្ត្រដែលអាចផ្ទៀងផ្ទាត់បាន ដែលបានរៀបចំឡើងក្នុងរយៈពេលមួយ និងតាមលទ្ធភាពដែលអាចធ្វើទៅបាន ការធ្វើឱ្យមានលក្ខណៈស្តង់ដាដើម្បីជួយវិនិយោគិន និងអ្នកប្រើប្រាស់ចំណាត់ថ្នាក់លទ្ធភាពសងផ្សេងទៀតធ្វើការប្រៀបធៀបភ្នាក់ងារវាយតម្លៃលទ្ធភាពសងផ្សេងៗគ្នាបាន។ ករណីលក្ខណៈនៃបុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុល ឬកាលៈទេសៈផ្សេងទៀតធ្វើឱ្យមានការផ្លាស់ប្ដូរជាប្រវត្តិសាស្ត្រ ឬអត្រានៃភាពមិនទូទាត់សងមានលក្ខណៈមិនសមរម្យ មិនត្រឹមត្រូវតាមស្ថិតិ ឬនាំឱ្យយល់ខុសដល់វិនិយោគិន ឬអ្នកប្រើប្រាស់ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងផ្សេងទៀត RAC ត្រូវបង្ហាញពីមូលហេតុទាំងនេះ។

## ខ. ការអនុវត្តចំពោះព័ត៌មានសម្ងាត់

៣.១៩ RAC ត្រូវបង្កើត រក្សា រក្សាទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដើម្បីការពារព័ត៌មានសម្ងាត់ និង/ឬព័ត៌មានសំខាន់ដែលមិនត្រូវបង្ហាញជាសាធារណៈ រួមទាំងព័ត៌មានសម្ងាត់ដែលទទួលបានពីបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល ឬអ្នកដឹកនាំដំណើរការបោះផ្សាយ ឬក្រុមហ៊ុនជានាទិញ ឬក្រុមអ្នកជានាទិញ អំពីសកម្មភាពវាយតម្លៃចំណាត់ថ្នាក់

លទ្ធភាពសង (ឧទាហរណ៍៖ ព័ត៌មានអំពីសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង មុនពេលចំណាត់ថ្នាក់លទ្ធភាពសងនោះត្រូវបានបង្ហាញជាសាធារណៈ ឬផ្សព្វផ្សាយដល់អ្នកធ្វើបរិវិសកម្ម)។

ក. គោលការណ៍ នីតិវិធី និងការត្រួតពិនិត្យត្រូវហាមឃាត់ RAC និងបុគ្គលិករបស់ខ្លួនពីការប្រើប្រាស់ ឬបង្ហាញព័ត៌មានសម្ងាត់ និង/ឬព័ត៌មានដែលមិនមែនជាសាធារណៈសម្រាប់គោលបំណងណាមួយ ដែលមិនទាក់ទងទៅនឹងសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC រួមទាំងការបង្ហាញព័ត៌មាននេះដល់បុគ្គលិកផ្សេងទៀតដែលការបង្ហាញព័ត៌មាននេះ មិនពាក់ព័ន្ធនឹងសកម្មភាពវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងរបស់ RAC ទេ លុះត្រាតែតម្រូវដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

ខ. គោលការណ៍ នីតិវិធី និងការគ្រប់គ្រងត្រូវតម្រូវឱ្យ RAC និងនិយោជិតរបស់ខ្លួនចាត់វិធានការសមហេតុផលដើម្បីការពារព័ត៌មានសម្ងាត់ និង/ឬព័ត៌មានដែលមិនមែនជាសាធារណៈពីការក្លែងបន្លំ ការលួច ការប្រើប្រាស់ខុស ឬការបង្ហាញព័ត៌មានដោយអចេតនា។

គ. ព័ត៌មានសម្ងាត់ដែលទទួលបានពីបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល អ្នកដឹកនាំដំណើរការបោះផ្សាយ ក្រុមហ៊ុនធានាទិញ ឬអ្នករៀបចំ គោលការណ៍ នីតិវិធី និងការគ្រប់គ្រងមិនត្រូវបានអនុញ្ញាតឱ្យ RAC និងបុគ្គលិករបស់ខ្លួនប្រើប្រាស់ ឬបង្ហាញព័ត៌មានទាំងនេះដោយបំពានលើលក្ខខណ្ឌនៃការអនុវត្តណាមួយ កិច្ចព្រមព្រៀង ឬការព្រមព្រៀងគ្នាទៅវិញទៅមកណាមួយឡើយ លើកលែងតែការបង្ហាញព័ត៌មានទាំងនោះត្រូវបានតម្រូវដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

ឃ. ចំពោះសកម្មភាពវាយតម្លៃលទ្ធភាពសងដែលមិនទាន់រួចរាល់ គោលការណ៍ នីតិវិធី និងការគ្រប់គ្រងមិនត្រូវបានអនុញ្ញាតឱ្យ RAC និងបុគ្គលិករបស់ខ្លួនធ្វើការផ្សព្វផ្សាយព័ត៌មានជាជម្រើសអំពីសកម្មភាពវាយតម្លៃឥណទានដែលមិនទាន់រួចរាល់នោះ លើកលែងតែបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល អ្នកដឹកនាំដំណើរការបោះផ្សាយ ក្រុមហ៊ុនធានាទិញ ឬអ្នករៀបចំដែលបានកំណត់ ឬត្រូវបានតម្រូវដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន។

៣.២០ RAC ត្រូវបង្កើត រក្សា រក្សាទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលបានរៀបចំឡើងដើម្បីការពារការរំលោភលើច្បាប់ និងបទប្បញ្ញត្តិជាធរមានដែលគ្រប់គ្រងលើការប្រើប្រាស់ព័ត៌មានសម្ងាត់ និង/ឬព័ត៌មានសំខាន់ដែលមិនត្រូវផ្សព្វផ្សាយជាសាធារណៈ។

៣.២១ RAC ត្រូវបង្កើត រក្សា រក្សាទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលហាមឃាត់បុគ្គលិកដែលមានព័ត៌មានសម្ងាត់ និង/ឬព័ត៌មានមិនសាធារណៈទាក់ទងនឹងឧបករណ៍ជួញដូរពីការចូលរួមក្នុងប្រតិបត្តិការនៅក្នុងឧបករណ៍ជួញដូរ ឬប្រើប្រាស់ព័ត៌មានដើម្បីផ្តល់ប្រឹក្សា ឬផ្តល់អត្ថប្រយោជន៍ដល់បុគ្គលម្នាក់ទៀតក្នុងការធ្វើប្រតិបត្តិការក្នុងឧបករណ៍ជួញដូរ។

## ៤. អភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងការបណ្តុះបណ្តាលបុគ្គលិក

៤.១ ក្រុមប្រឹក្សាភិបាលរបស់ RAC (ឬស្ថាប័នស្រដៀងគ្នា) ត្រូវមានទំនួលខុសត្រូវខ្ពស់បំផុតក្នុងការធានាថា RAC បង្កើត ថែរក្សា រក្សាទុកជាឯកសារ និងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈដែលផ្តល់ឥទ្ធិពលពេញលេញដល់ក្រមប្រតិបត្តិ IOSCO ដែលជាមូលដ្ឋានសម្រាប់ភ្នាក់ងារវាយតម្លៃលទ្ធភាពសង។

៤.២ RAC ត្រូវបង្កើតមុខងារគ្រប់គ្រងហានិភ័យដែលបង្កើតឡើងដោយអ្នកគ្រប់គ្រងជាន់ខ្ពស់មួយរូប ឬបុគ្គលិកដែលមានកម្រិតបទពិសោធន៍សមស្របដែលទទួលខុសត្រូវក្នុងការកំណត់អត្តសញ្ញាណ វាយតម្លៃ ការត្រួតពិនិត្យ និងរាយការណ៍ពីហានិភ័យដែលកើតឡើងពីសកម្មភាពរបស់ខ្លួន រួមទាំង ប៉ុន្តែមិនកំណត់ចំពោះហានិភ័យផ្នែកច្បាប់។ ហានិភ័យកេរ្តិ៍ឈ្មោះ ហានិភ័យប្រតិបត្តិការ និងហានិភ័យយុទ្ធសាស្ត្រ។ មុខងារនេះត្រូវតែឯករាជ្យពីមុខងារសវនកម្មផ្ទៃក្នុង (ប្រសិនបើអាចអនុវត្តបានតាមទំហំរបស់ RAC) និងធ្វើរបាយការណ៍តាមកាលកំណត់ទៅក្រុមប្រឹក្សាភិបាល (ឬស្ថាប័នស្រដៀងគ្នា) និងអ្នកគ្រប់គ្រងជាន់ខ្ពស់ដើម្បីជួយពួកគេក្នុងការវាយតម្លៃភាពគ្រប់គ្រាន់នៃគោលនយោបាយ នីតិវិធី និងការគ្រប់គ្រង RAC បង្កើត ថែរក្សា រក្សាទុកជាឯកសារ និងពង្រឹងការគ្រប់គ្រងហានិភ័យ រួមទាំងគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលបានបញ្ជាក់នៅក្នុង IOSCO ក្រមប្រតិបត្តិជាមូលដ្ឋានសម្រាប់ភ្នាក់ងារវាយតម្លៃលទ្ធភាសង។

៤.៣ RAC ត្រូវបង្កើត រក្សា រក្សាទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យដែលតម្រូវឱ្យនិយោជិតទទួលការបណ្តុះបណ្តាលបន្តជាផ្លូវការឱ្យបានជាប្រចាំ។ ប្រធានបទដែលត្រូវធ្វើការបណ្តុះបណ្តាលត្រូវពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់បុគ្គលិក ហើយត្រូវពាក់ព័ន្ធនឹងក្រមសីលធម៌របស់ RAC វិធីសាស្ត្រវាយតម្លៃលទ្ធភាពសងរបស់ RAC ច្បាប់គ្រប់គ្រងសកម្មភាពវាយតម្លៃលទ្ធភាពសងរបស់ RAC គោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យរបស់ RAC ។ សម្រាប់ការគ្រប់គ្រងទំនាស់ផលប្រយោជន៍ និងគ្រប់គ្រងការកាន់កាប់ និងធ្វើប្រតិបត្តិការជួញដូរមូលបត្រណាមួយ និងគោលនយោបាយ និងនីតិវិធីរបស់ RAC សម្រាប់ការគ្រប់គ្រងព័ត៌មានសម្ងាត់ និង/ឬព័ត៌មានសំខាន់ដែលមិនត្រូវផ្សព្វផ្សាយជាសាធារណៈ។ គោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យត្រូវរួមបញ្ចូលវិធានការដែលបានរៀបចំឡើងដើម្បីផ្ទៀងផ្ទាត់ថាបុគ្គលិកបានទទួលការបណ្តុះបណ្តាលដែលចាំបាច់។

## ៥. ការបង្ហាញព័ត៌មាន និងទំនាក់ទំនងជាមួយអ្នកចូលរួមទីផ្សារ

៥.១ ការបង្ហាញព័ត៌មានរបស់ RAC រួមទាំងអ្វីដែលបានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិនៃ IOSCO CRA Code ត្រូវតែពេញលេញ យុត្តិធម៌ ត្រឹមត្រូវ ទាន់ពេលវេលា និងងាយយល់សម្រាប់វិនិយោគិន និងអ្នកប្រើប្រាស់ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសងផ្សេងទៀត។

៥.២ RAC ត្រូវបង្ហាញនូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួននូវការពិពណ៌នាអំពីរបៀបដែលបទប្ប ញ្ញត្តិនៃក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន អនុវត្តតាមយ៉ាងពេញលេញនូវបទប្បញ្ញត្តិនៃសេចក្តីថ្លែងការណ៍របស់ IOSCO អំពីគោលការណ៍ទាក់ទងនឹងសកម្មភាពរបស់ភ្នាក់ងារវាយតម្លៃលទ្ធភាពសង និងក្រមប្រតិបត្តិ IOSCO ជាមូលដ្ឋានសម្រាប់ភ្នាក់ងារវាយតម្លៃលទ្ធភាពសង ( "បទប្បញ្ញត្តិ IOSCO") ។ ករណីក្រមសីលធម៌វិជ្ជាជីវៈរបស់ RAC ខុសពីបទប្បញ្ញត្តិរបស់ IOSCO នោះ RAC នឹងកំណត់ពីបទប្បញ្ញត្តិ IOSCO ដែលពាក់ព័ន្ធ ពន្យល់ពីមូលហេតុនៃភាពខុសគ្នា និងពន្យល់ពីរបៀបនៃការខុសគ្នានេះដែលមាននៅក្នុងបទប្បញ្ញត្តិ IOSCO ។ RAC ត្រូវពណ៌នាអំពីវិធីអនុវត្ត និងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ RAC ក៏ត្រូវបង្ហាញព័ត៌មានឱ្យបានទាប់នូវការផ្លាស់ប្តូរចំពោះក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន ឬការផ្លាស់ប្តូរវិធីអនុវត្ត ឬការអនុវត្ត។

៥.៣ RAC ត្រូវបង្កើត និងរក្សាមុខងារមួយនៅក្នុងអង្គភាពរបស់ខ្លួន ដោយទទួលខុសត្រូវក្នុងការទទួលរក្សាទុក និងដោះស្រាយពាក្យបណ្តឹងពីអ្នកចូលរួមទីផ្សារ និងសាធារណជន។ មុខងារនេះត្រូវបង្កើត រក្សា រក្សាទុកជាឯកសារ និងអនុវត្តគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការទទួលរក្សាទុក និងដោះស្រាយបណ្តឹង រួមទាំងឯកសារដែលត្រូវបានផ្តល់ជាសម្ងាត់។ គោលនយោបាយ នីតិវិធី និងការគ្រប់គ្រងត្រូវបញ្ជាក់អំពីកាលៈទេសៈដែលពាក្យបណ្តឹងត្រូវតែរាយការណ៍ទៅអ្នកគ្រប់គ្រងជាន់ខ្ពស់ និង/ឬក្រុមប្រឹក្សាភិបាល (ឬស្ថាប័នស្រដៀងគ្នា)។

៥.៤ RAC ត្រូវបង្ហាញជាសាធារណៈ និងដោយមិនគិតថ្លៃនៅលើគេហទំព័ររបស់ខ្លួន៖

ក. ក្រមសីលធម៌វិជ្ជាជីវៈរបស់ RAC;

ខ. ការពិពណ៌នាអំពីវិធីសាស្រ្តវាយតម្លៃលទ្ធភាពសងរបស់ RAC;

គ. ព័ត៌មានអំពីទិន្នន័យប្រតិបត្តិការជាប្រវត្តិសាស្រ្តរបស់ RAC; និង

ឃ. ការបង្ហាញផ្សេងទៀតដែលបានបញ្ជាក់នៅក្នុងបទប្បញ្ញត្តិនៃក្រម IOSCO ដូចដែលអាចអនុវត្តបានដែលបានផ្តល់ឱ្យគំរូអាជីវកម្មរបស់ RAC ។

## និយមន័យ

និយមន័យដែលមាននៅក្នុងក្រមសីលធម៌វិជ្ជាជីវៈនេះ៖

"**សមាគារី**" សំដៅដល់អង្គភាពដែលគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ត្រូវបានគ្រប់គ្រងដោយ ឬស្ថិតនៅក្រោមការគ្រប់គ្រងរួមជាមួយនឹងអង្គភាពមួយផ្សេងទៀត។

"**អ្នកវិភាគ**" សំដៅដល់បុគ្គលិករបស់ RAC ដែលបំពេញមុខងារវិភាគដែលចាំបាច់សម្រាប់ការចេញ ឬត្រួតពិនិត្យការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង ឬចូលរួមក្នុងការកំណត់ចំណាត់ថ្នាក់លទ្ធភាពសង រួមទាំងបុគ្គលិកដែលចូលរួមនៅក្នុងគណៈកម្មាធិការវាយតម្លៃលទ្ធភាពសងផងដែរ។

"**ការវាយតម្លៃលទ្ធភាពសង**" ឬ "**ការវាយតម្លៃ**" សំដៅដល់ការវាយតម្លៃទាក់ទងនឹងភាពសក្តិសមនៃឥណទានរបស់បុគ្គលរងចំណាត់ថ្នាក់ ឬបុគ្គលជាប់កាតព្វកិច្ចបំណុលដែលបង្ហាញដោយប្រើប្រព័ន្ធចំណាត់ថ្នាក់ដែលបានបង្កើតឡើង និងបានកំណត់។

"**សកម្មភាពវាយតម្លៃឥណទាន**" សំដៅដល់ការកំណត់ចំណាត់ថ្នាក់លទ្ធភាពសងដំបូង ការដំឡើងចំណាត់ថ្នាក់លទ្ធភាពសងដែលមានស្រាប់ ការបន្ទាបចំណាត់ថ្នាក់លទ្ធភាពសងដែលមានស្រាប់ (រួមទាំងការមិនទូទាត់សង) ការបញ្ជាក់ពីចំណាត់ថ្នាក់លទ្ធភាពសងដែលមានស្រាប់ ឬការដកចំណាត់ថ្នាក់លទ្ធភាពសង។

"**ភ្នាក់ងារវាយតម្លៃលទ្ធភាពសង**" ឬ "CRA" សំដៅដល់អង្គភាពដែលមានអាជីវកម្មពាក់ព័ន្ធនឹងការចេញចំណាត់ថ្នាក់លទ្ធភាពសង។

"**វិធីសាស្ត្រវាយតម្លៃលទ្ធភាពសង**" សំដៅដល់នីតិវិធីដែល RAC កំណត់ការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង រួមទាំងព័ត៌មានដែលត្រូវតែពិចារណា ឬវិភាគដើម្បីកំណត់ចំណាត់ថ្នាក់លទ្ធភាពសង និងក្របខណ្ឌវិភាគដែលប្រើដើម្បីកំណត់ចំណាត់ថ្នាក់លទ្ធភាពសងរួមទាំងគំរូតាមដែលអាចអនុវត្តបាន រង្វាស់ហិរញ្ញវត្ថុ ការសន្មត់ លក្ខណៈវិនិច្ឆ័យ ឬកត្តាបរិមាណ ឬគុណភាពផ្សេងទៀតដែលត្រូវប្រើដើម្បីកំណត់ចំណាត់ថ្នាក់លទ្ធភាពសង។

"**ដំណើរការវាយតម្លៃលទ្ធភាពសង**" សំដៅដល់សកម្មភាពវាយតម្លៃលទ្ធភាពសង រួមមាន ការជ្រើសរើស និងការចាត់តាំងអ្នកវិភាគរបស់ RAC ដើម្បីឱ្យធ្វើការលើបញ្ហា ការអនុវត្តវិធីសាស្ត្រវាយតម្លៃលទ្ធភាពសង សកម្មភាពធ្វើការសម្រេចចិត្ត (ឧ. ប្រតិបត្តិការនៃគណៈកម្មាធិការវាយតម្លៃ) អន្តរកម្មជាមួយបុគ្គលរងចំណាត់ថ្នាក់ បុគ្គលជាប់កាតព្វកិច្ចបំណុល អ្នកដឹកនាំដំណើរការបោះផ្សាយ ក្រុមហ៊ុនធានាទិញ ឬក្រុមអ្នកធានាទិញ ហើយតាមដែលអាចអនុវត្តបាន ការផ្សព្វផ្សាយចំណាត់ថ្នាក់លទ្ធភាពសងសាធារណៈ ឬចំពោះអ្នកធ្វើបរិវិសកម្ម។

"**បុគ្គលិក**" សំដៅដល់បុគ្គលដែលបំរើការឱ្យ RAC ពេញម៉ោង ក្រៅម៉ោង ឬបណ្ដោះអាសន្ន រួមទាំងបុគ្គលដែលជាប់កិច្ចសន្យា ដែលបុគ្គលទាំងនោះមានជាប់ពាក់ព័ន្ធក្នុងដំណើរការវាយតម្លៃចំណាត់ថ្នាក់លទ្ធភាពសង។

“**អង្គភាព**” សំដៅដល់រដ្ឋាភិបាល អ្នកនយោបាយ ភ្នាក់ងារ ឬឧបករណ៍របស់រដ្ឋាភិបាល; ឬក្រុមហ៊ុន សាជីវកម្ម ភាពជាដៃគូ បរធនបាល អចលនទ្រព្យ ឬសមាគម។

“**ឧបករណ៍ជួញដូរ**” សំដៅដល់ មូលបត្រ ឧបករណ៍ទីផ្សាររូបិយវត្ថុ ឧបករណ៍និស្សន្ទ ឬផលិតផលស្រដៀងគ្នាផ្សេងទៀត។

“**ឧបករណ៍បំណុល**” សំដៅដល់ ឧបករណ៍ជួញដូរ ការសន្យាឥណទាន ប្រាក់កម្ចី ឬផលិតផល ឬប្រតិបត្តិការស្រដៀងគ្នាផ្សេងទៀតដែលមានហានិភ័យឥណទាន។

“**បុគ្គលជាប់កាតព្វកិច្ចបំណុល**” សំដៅដល់ អង្គភាពដែលមានកាតព្វកិច្ចស្របច្បាប់ ឬតាមកិច្ចសន្យាដើម្បីធ្វើការទូទាត់លើកាតព្វកិច្ចវាយតម្លៃ។